## ធាតុផ្សំរួមនៃបទឧក្រិដ្ឋ (chapeau elements)

បទឧក្រិដ្ឋកម្មក្រោមច្បាប់អន្តរជាតិ (international crime) មានភាពស្មុគស្មាញ និងច្រើនប្រភេទ។ ដូចនេះ ច្បាប់បានចែកជាធាតុផ្សំរួម ក្នុងចង្កោមបទឧក្រិដ្ឋចំនួនបីគឺ៖ បទឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ (crime against humanity) ប្រល័យពូជសាសន៍ (genocide) ឧក្រិដ្ឋកម្មសង្គ្រាម (war crime)។

បទឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ មានធាតុផ្សំយ៉ាងតិចចំនួន ៥៖ ១. ការវាយប្រហារ (attack)។ ២. ទង្វើរបស់ជនល្មើស ជាផ្នែកមួយនៃការវាយប្រហារ។ ៣. ការវាយប្រហារទៅលើជនស៊ីវិល។ ៤. ការវាយប្រហារមានលក្ខណៈទូទៅ ឬ ជាប្រព័ន្ធ (widespread or systematic) និងទី៥. ជនល្មើសបានដឹងថា ទង្វើរបស់ខ្លួនជាផ្នែកមួយនៃការវាយប្រហារទូទៅ (*tadic*, IT-94-1-A, 1999, S. 248-251)។

ក្រោមធាតុផ្សំរួមនេះ មានបទល្មើសដោយឡែកៗ ដែលមានធាតុផ្សំផ្សេងៗតាមការកំណត់ដោយយុត្តិសាស្ត្រ ឬច្បាប់។ ជាក់ស្តែង ក្រោមបទឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ មានបទល្មើសធ្វើទុក្ខបុកម្នេញ (persecution) ដែលមានធាតុផ្សំ ការដកហូតសិទ្ធិចម្បង (ធាតុសំភារៈ) និងចេតនារើសអើង (discrimination) បន្ថែមដោយធាតុផ្សំរួមនៃបទឧក្រិដ្ឋកម្មនេះ ដូចជា ការវាយប្រហារជាផ្នែកនៃការវាយប្រហារជាទូទៅលើជនស៊ីវិល (elements of crimes)។